Ottawa County Health Department

# សន្លឹកព័ត៌មានសាធារណៈ

## រោគថ្លើមប្រភេទ C [HEPATITIS C]

### តើរោគថ្លើមប្រភេទ C គឺជាអ្វី?

រោគថ្លើមប្រភេទC គឺជារោគមួយ បង្កដោយវីរុស ដែលប៉ះពាល់ដល់ថ្លើម ។ ចំនួន 80% នៃអ្នកមានរោគថ្លើមប្រភេទC  មិនមានរោគសញ្ញាទេ ។

### តើរោគថ្លើមប្រភេទ C ត្រូវបានឆ្លងយ៉ាងដូចម្តេច?

រោគថ្លើមប្រភេទ C ត្រូវបានឆ្លងតាមរយៈរបៀបទាំងឡាយខាងក្រោមនេះ:

- ឈាមពីអ្នកមានរោគនេះចូលរូបកាយនៃមនុស្សដែលមិនទាន់មានរោគទេ ។ ការនេះអាចកើតឡើងបានតាមវិធីជាច្រើន រួមទាំង:
- ចែកម្ជុលជាមួយអ្នកមានតើរោគថ្លើមប្រភេទ C
- រួមរ័កជាមួយអ្នកមានរោគថ្លើមប្រភេទ C
- ឆ្លងពីម្តាយទៅកូននៅពេលឆ្លងទន្លេ
- ចែកច្រាសដុសធ្មេញជាមួយអ្នកមានរោគថ្លើមប្រភេទ C
- ទទួលឈាម ឬផលិតផលឈាមពីអ្នកមានរោគថ្លើមប្រភេទ C ។ (ការពិនិត្យឈាមរកមេរោគថ្លើមប្រភេទ C ដ៏ទៀងទាត់ មិនបានចាប់ផ្តើមនៅប្រទេសសហរដ្ឋអាមេរិក រហូតដល់ខែកក្កដា ឆ្នាំ 1992 ។)
- ត្រងឈាមដោយម៉ាស៊ីន អស់រយៈពេលដ៏យូរ

### តើអាចមានមេរោគអ្វីខ្លះ?

រោគសញ្ញាអាចមានរួមទាំង:

- ភ្នែក ឬស្បែកពណ៌លឿង
- ការនឿយហត់យ៉ាងខ្លាំង
- ទឹកនោមពណ៌ចាស់
- ឈឺក្រពះ
- លែងចង់បរិភោគអាហារ
- ក្អួត និងមានអារម្មណ៍ចង់ក្អួត

### តើរោគថ្លើមប្រភេទ C ត្រូវបានវិនិច្ឆ័យរោគយ៉ាងដូចម្តេច?

ដោយការពិនិត្យឈាមរករោគថ្លើមប្រភេទ C ។

### តើរោគថ្លើមប្រភេទ C ត្រូវបានព្យាបាលយ៉ាងដូចម្តេច?

គ្មានវិធីព្យាបាលរោគថ្លើមប្រភេទ Cឱ្យជាទេ ។ អ្នកកើតរោគថ្លើមប្រភេទ C ជាងពាក់កណ្តាល និងមានរោគថ្លើមប្រភេទ C អស់មួយជីវិត ។ ក្នុងចំណោមអ្នកមានរោគអស់មួយជីវិត ចំនួន 70% នឹងកើតរោគថ្លើមរ៉ាំរ៉ៃដទៃទៀតដែរ ។ អ្នកជម្ងឺខ្លះ ទទួលប្រយោជន៍ពីថ្នាំពេទ្យមួយចំនួន ។

### តើអាចបង្ការរោគថ្លើមប្រភេទ C បានយ៉ាងដូចម្តេច?

- កុំប៉ះពាល់ឈាម ឬផលិតផលឈាម
- កុំចាក់ថ្នាំញៀន ឬចែកម្ជុលជាមួយអ្នកផ្សេង
- កុំចែករបស់ថែទាំអនាម័យផ្ទាល់ខ្លួន ដូចជាច្រាសដុសធ្មេញ ឬឡាម ជាមួយអ្នកដទៃ
- បើលោកអ្នកមានរោគថ្លើមប្រភេទ C  នោះកុំបរិច្ចាគឈាម ឬសរីរាង្គឡើយ
- គ្មានថ្នាំបង្ការរោគថ្លើមប្រភេទ C ទេ

### សម្រាប់ព័ត៌មានបន្ថែមអំពីរោគថ្លើមប្រភេទ C:

Ottawa County Health Department
www.miOttawa.org
Center for Disease Control and Prevention
www.cdc.gov/ncidod/diseases/hepatitis/c/ fact.htm
ទូរស័ព្ទ: (888) 246-2675
Michigan Department of Community Health
http://www.michigan.gov/documents/mdch/Hepatitis_C_Fact_Sheet_196974_7.pdf
Medline Plus/National Institutes of Health
http://www.nlm.nih.gov/medlineplus/ency/article/000284.htm

12251 James St., Suite 400
Holland, MI  49424
ទូរស័ព្ទ: (616) 396-5266
ទូរសារ:  (616) 393-5643
វ៉ិបសាយ: www.miOttawa.org